# អំពើអនីត្យានុកូល (មូលហេតុកៀកកិត)
## Tort (Proximate Cause)

មានមូលហេតុជាច្រើនចូលរួមបង្កនូវការខូចខាត។ ជាក់ស្តែង បុគ្គលម្នាក់បានបើកបរទៅប៉ះបុគ្គលម្នាក់ ក៏ប៉ុន្តែមិនបានបង្កជារបួសស្នាមទេ ៥ម៉ោងក្រោយមក ជនទីពីរនេះ បានដើរទៅជំពប់ជើងលើសំភារះរបស់អ្នកទីបីទុកចោលនៅលើផ្លូវ ធ្វើឲ្យគាត់ទទួលរងរបួសជើង។ គាត់បានប្តឹងអ្នកបើកបរ ថាជាអ្នកបង្កឲ្យមានរបួសជើង។

តុលាការជាន់ទាប (district court) បានបដិសេធនូវពាក្យបណ្តឹងនេះ។ ចុងចម្លើយបានប្តឹងទៅសាលាឧទ្ធរណ៍។ សាលាឧទ្ធរណ៍ បានអះអាងថា អ្នកប្តឹងមានបន្ទុកភស្តុតាង (burden of proof) បង្ហាញថារបួសស្ថិតក្នុងហានិភ័យដែលអាចប្រមើលឃើញដោយសមហេតុសមផល (reasonable foreseeable) បង្កើតដោយចុងចម្លើយ។ ក្នុងន័យនេះ ទង្វើអ្នកទីបី (ទុកសំភារះលើផ្លូវដោយធ្វេសប្រហែស) នឹងមិនឲ្យអ្នកប្រព្រឹត្តដំបូង (អ្នកបើកបរ) រួចផុតពីការទទួលខុសត្រូវលើអំពើអនីត្យានុកូលនេះទេ ប្រសិនបើទង្វើនោះ អាចត្រូវបានប្រមើលឃើញដោយសមហេតុសមផល[1]។

ទោះបីជាយ៉ាងនេះក្តី រយៈពេល៥ម៉ោងបានកន្លងទៅ អ្នកបើកបរមិនអាចព្យាករថា ជនរងគ្រោះរងរបួសដោយសារដើរជំពប់ជើង។ របួសជើងបណ្តាលមកពីភ្នាក់ងារដាច់ដោយឡែក (independent agency) ផលវិបាកនៃទង្វើរបស់អ្នកបើកបរបានបញ្ចប់ទៅហើយ។ សាលាឧទ្ធរណ៍បានយោងដល់ តុលាការកំពូល Massa-chusetts ដែលទំនងបដិសេធនូវទ្រឹស្តី *"អាចប្រមើលឃើញសមហេតុសមផល" ក្នុងខ្លឹមសារថា៖ វាត្រូវតែមាននូវការកម្រិតចំពោះវិសាលភាព ឬនិយមន័យនៃការអាចប្រមើលឃើញសមហេតុសមផល ផ្អែកតាមការពិចារណាលើការវិនិច្ឆ័យតាមករណីជាក់ស្តែង...*[2]។ សាលាឧទ្ធរណ៍បានគាំទ្រសាលក្រមរបស់តុលាការជាន់ទាប។

**កំណត់សំគាល់៖** មាត្រា៧៤២នៃក្រមរដ្ឋប្បវេណីកម្ពុជា ចែងអំពីការទទួលខុសត្រូវលើអំពើអនីត្យានុកូល ដោយសារកំហុសចេតនាឬអចេតនា (ចំណុចក. *ធ្វើអំពើបំពានដោយព្យាករទុកជាមុនអំពីការកើត*

---

[1]Generally, intervening negligent conduct of a third person will not relieve the original tortfeasor from liability where such conduct was reasonably foreseeable. *Poskus, 423 Mass. at 639-40, 670 N.E.2d 383)*, Judith A. McMorrow, Introduction to Torts: Injury Law in the United States, 2018, p. 151.

[2] there must be limits to the scope or definition of reasonable foreseeability based on considerations of policy and pragmatic judgment." *Poskus, 423 Mass. at 640, 670 N.E.2d 383*; *see also Kent, 437 Mass. at 320-21, 771 N.E.2d 770*; Dan B. Dobbs, *The Law of Torts*, ch. 10, § 180, at 443 (2001) ("The proximate cause issue, in spite of the terminology, is not about causation at all but about the appropriate scope of responsibility.").

*ឡើងនៃលទ្ធផល ហើយដោយទទួលយកការកើតឡើងនៃលទ្ធផលនោះ..*) ។ ខ្លឹមសារនេះស្រដៀងនឹងការអាចប្រមើលឃើញសមហេតុសមផល ទោះបីជាយ៉ាងនេះក្តី ជំពូកទី១៦ទាំងស្រុងស្តីពីអំពើអនីត្យានុកូលនេះ មិនបានចែងលម្អិតអំពីលក្ខណៈវិនិច្ឆ័យអំពីករណីចំពោះ "ភាពអាចប្រមើលឃើញសមហេតុសមផល"។ ខ្លឹមសារសោលដីកាខាងលើអាចជួយបំភ្លឺករណីនេះ។

សម្រាប់អត្ថបទពាក់ព័ន្ធដទៃទៀតសូមមើល៖ សំណាងរួមគ្នា ការទទួលខុសត្រូវលើអំពើអនីត្យានុកូល។